ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
លេខៈ ០០១ / សសរ .អ.ជ.ប.គ.ញ

# សេចក្តីសំរេច
# ការបង្កើតក្រុមការងារអន្តរក្រសួង
# របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

********

## អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨
- ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៥ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦
- ស្តីពីការកែសំរួលព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥
- ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- តាមសំណើរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## <u>សំរេច</u>

ប្រការ១: ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង របស់អាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន ដូចមានសមាសភាពខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម ឧត្តមសេនីយ៍ឯក លួ រ៉ាមីន | អនុប្រធានអចិន្ត្រៃយ៍ នៃ អ.ជ.ប.គ.ញ | ប្រធាន |
| ២- ឯកឧត្តម អ៊ុំក រ៉ាប៊ុន | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម ហ៊ី សោភា | រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤- ឯកឧត្តម ឧត្តមសេនីយ៍ឯក មុឹក ដារ៉ា | អគ្គលេខាធិការ នៃ អ.ជ.ប.គ.ញ | អនុប្រធាន |
| ៥- ឯកឧត្តម ជ័យ ចាប | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៦- ឯកឧត្តម ជូ យិនស៊ឹម | រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ៧- ឯកឧត្តម ចក់ ឡេង | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨- ឯកឧត្តម ឈឹម ជួន | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៩- ឯកឧត្តម ឧត្តមសេនីយ៍ឯក ឈុំ សុជាតិ | អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ១០- ឯកឧត្តម សុទ្ធ សុធន | អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

១១- ឯកឧត្តម ផាត់ សារ៉េត អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន សមាជិក

១២- ឯកឧត្តម គឹម សោភ័ណ្ឌ អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

១៣- ឯកឧត្តម ស៊ា ហួច អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល សមាជិក

១៤- ឯកឧត្តម សយ គីរម្យ អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

១៥- ឯកឧត្តម ផាត់ ហួរ អគ្គលេខាធិការ ធនាគារជាតិនៃកម្ពុជា សមាជិក

១៦- ឯកឧត្តម គង់ ឆាន អគ្គនាយករង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

១៧- ឯកឧត្តម ស ឆាំរិទ្ធ ទីប្រឹក្សា នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក

សមាសភាពក្រុមការងារខាងលើនេះ ជាជំនួយការរដ្ឋមន្ត្រីឬប្រធានស្ថាប័ននីមួយៗរបស់ខ្លួន ។ ប្រធានក្រុមការងារខាងលើនេះ មានសិទ្ធិអញ្ជើញសមាជិកក្រុមការងារតាមបណ្តាលក្រសួង ឬ ស្ថាប័ននីមួយៗ ជាសមាជិក អ.ជ.ប.គ.ញ មកចូលរួមប្រជុំរាល់ការងារសំខាន់ៗ និងចាំបាច់របស់អាជ្ញាធរជាតិប្រយុទ្ធ ប្រឆាំងគ្រឿងញៀន ។

ក្រុមការងារខាងលើ ត្រូវរាយការណ៍ផ្ទាល់ជូនរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នរបស់ខ្លួនដើម្បីជ្រាប ឬ ស្នើ សុំយោបល់នូវលទ្ធផលនៃកិច្ចប្រជុំ ។

ប្រការ២: ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសមួយសំរាប់ជាសេនាធិការអោយក្រុមការងារអន្តរក្រសួងរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដូចមានសមាសភាពខាងក្រោម ៖

១- ឯកឧត្តម ឧត្តមសេនីយ៍ឯក ម៉ឹក ដារ៉ា អគ្គលេខាធិការ នៃ អ.ជ.ប.គ.ញ ប្រធាន

២- ឯកឧត្តម ជួច សំគី អគ្គនាយក ក្រសួងយុត្តិធម៌ អនុប្រធាន

៣- ឯកឧត្តម ស ឆាំរិទ្ធ ទីប្រឹក្សា នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អនុប្រធាន

៤- ឯកឧត្តម ស ថេង អគ្គនាយករង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សមាជិក

៥- ឯកឧត្តម ឆាយ សាវុធ ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៦- លោក ប៉ាន់ ចាន់ឡាវ័ន្ត អគ្គនាយករង រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

៧- លោក ស៊ីវ ស៊ីនី អគ្គនាយករង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៨- លោកជំទាវ អ៊ីវ ស្រី ប្រធាននាយកដ្ឋានផែនការ និងបណ្តុះបណ្តាល សមាជិក

៩- លោក នាក់ យុទ្ធា ប្រធាននាយកដ្ឋាននីតិកម្ម អប់រំ និងស្តារនីតិសម្បទា សមាជិក

១០- លោក សិទ្ធិ សាគល ប្រធាននាយកដ្ឋានសុវត្ថិសុខ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

១១- លោក ផ្លុំ ណាល់ ប្រធាននាយកដ្ឋាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

១២- លោក សឹង បញ្ញាវុឌ្ឍ ប្រធាននាយកដ្ឋានកិច្ចការអយ្យការ ក្រសួងយុត្តិធម៌ សមាជិក

១៣- លោក ម៉ែន សារឿន ប្រធាននាយកដ្ឋានសុខភាពសិក្សា ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១៤- លោក ឱុយ សុខចេង ប្រធាននាយកដ្ឋាននីតិកម្ម ក្រសួងព័ត៌មាន សមាជិក

១៥- លោក នង ស៊ីណា អនុប្រធាននាយកដ្ឋានប្រតិបត្តិការអន្តរជាតិ ក្រសួងព័ត៌មាន សមាជិក

១៦- ឧត្តមសេនីយ៍ទោ ស៊ិន ថាវ័ន្ត នាយរង នាយកដ្ឋានអធិការកិច្ច ក្រសួងការពារជាតិ សមាជិក

១៧- ឧត្តមសេនីយ៍ត្រី **ខៀវ សាម៉ន** អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន សមាជិក

១៨- លោក **សុខ ជា** អនុប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៩- លោកឱសថការី **ហេង ប៊ុនគៀត** អនុប្រធាននាយកដ្ឋាន ក្រសួងសុខាភិបាល សមាជិក

២០- លោក **គិច សៀកខន** តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

២១- លោក **ហ៊ី សំណាង** អនុប្រធាននាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា សមាជិក

ក្រុមការងារបច្ចេកទេសខាងលើនេះ ជាជំនួយការក្រុមការងារអន្តរក្រសួងរបស់ អ.ជ.ប.គ.ញ តាមភារកិច្ចដែលពាក់ព័ន្ធ ។ ប្រធានក្រុមការងារបច្ចេកទេសមានសិទ្ធិអញ្ជើញសមាជិកក្រុមការងារ របស់ខ្លួន មកចូលរួមប្រជុំរាល់ការងារដែលចាំបាច់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

សមាជិក សមាជិកាក្រុមការងារបច្ចេសទេសត្រូវរាយការណ៍ទៅសមាជិកក្រុមការងារអន្តរក្រសួង តាមក្រសួងឬស្ថាប័នរបស់ខ្លួន ដើម្បីជូនជ្រាប ឬស្នើសុំយោបល់ រាល់លទ្ធផលនៃកិច្ចប្រជុំ ។

**ប្រការ៣:** សេចក្តីសំរេចណាដែលផ្ទុយពីសេចក្តីសរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤:** រដ្ឋមន្ត្រី ប្រធានស្ថាប័នជាសមាជិក នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន , អគ្គលេខា ធិការដ្ឋាន នៃ អ.ជ.ប.គ.ញ និងសាមីខ្លួនដែលមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវអនុវត្ត តាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**<u>ចំលងជូន:</u>**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋមន្ត្រីក្រសួង. ប្រធានស្ថាប័ន ជាសមាជិកនៃ អ.ជ.ប.គ.ញ
  (ដើម្បីជូនជ្រាប)
- ដូចប្រការ១ និងប្រការ២ ( ដើម្បីអនុវត្ត)
- ឯកសារ - កាលប្បវត្តិ